**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
# ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
# ថ្លែងក្នុងឱកាសបើក
# សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៩

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩**

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកធ្វើជាអធិបតីក្នុងពិធីបើកសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៩ ដ៏មានសារៈសំខាន់ នាទីស្តីការគណៈរដ្ឋមន្ត្រីដ៏សែនមនោរម្យ បន្ទាប់ពីកិច្ចប្រជុំពេញអង្គ ដែលបានប្រព្រឹត្តទៅកាលពីម្សិលមិញ។ ក្នុងឱកាសដ៏ប្រពៃនេះ ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវអំណរគុណចំពោះវត្តមានដ៏មានតម្លៃរបស់ ឯកឧត្តម លោកជំទាវ លោក លោក ស្រី នាងកញ្ញា ដែលចូលរួមបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងលើកទិសដៅសកម្មភាពសម្រាប់ឆ្នាំ ២០២០ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជារបស់យើង។

ក្នុងរយៈពេលមួយឆ្នាំនេះ យើងបានបំពេញភារកិច្ចយ៉ាងសកម្មរួមគ្នា ដើម្បីឈានទៅបញ្ចប់ការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងដំណាក់កាលដែលស្ថានភាពជំនួយពីបរទេសធ្លាក់ចុះ។ នៅក្នុងរយៈពេលផ្ទេរដំណាក់កាលនេះ យើងទាំងអស់គ្នាចាប់ផ្តើមបំពេញតួនាទីក្នុងភាពជាម្ចាស់ ដោយប្តេជ្ញារួបរួមគ្នាបញ្ចប់នូវការឆ្លងរីករាលដាលមេរោគអេដស៍នៅកម្ពុជា ក្នុងឆ្នាំ២០២៥-២០៣០។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ជាមួយគ្នានេះផងដែរ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកាអង្គសន្និបាតជ្រាបថា កាលពីម្សិលមិញ យើងទាំងអស់គ្នាបានជួបជុំគ្នានៅក្នុង "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០១៩**" ដោយបានអនុម័តរួចទៅហើយ នូវផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ក្នុងឆ្នាំ២០១៩-២០២៣ ហើយនៅក្នុងអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅព្រឹកនេះយើងនឹងមានរបៀបវារៈថ្មីមួយទៀត ដើម្បីធ្វើបទបង្ហាញជូនអង្គសន្និបាតរួមមាន បទបង្ហាញរបស់ក្រសួងផែនការទាក់ទងនឹងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បទបង្ហាញទាក់ទងនឹងសេចក្ដីជូនដំណឹងលេខ ២១៣សជណ.សស ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជាហើយដែលការងារនេះបាន និងកំពុងអនុវត្តបន្ត ដែលបង្ហាញជូនដោយលោកស្មៀនឃុំព្រែកអំបិល វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់ខេត្តត្បូងឃ្មុំ កំពង់ចាម និងខេត្តស្វាយរៀង រួមនឹងបទបង្ហាញរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគផងដែរ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំមានជំនឿថា រយៈពេលពេញមួយព្រឹកនេះ អង្គសន្និបាតរបស់យើងនឹងទទួលបានចំណេះដឹង ជំនាញ និងបទពិសោធន៍ថ្មីៗ ដែលបានមកពីការអនុវត្តជាក់ស្តែង របស់សមាជិកសមាជិកានៃអង្គសន្និបាតទាំងមូលដែលអាចយកទៅប្រើប្រាស់ក្នុងការកែលម្អដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និង ជំងឺអេដស៍នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត របស់ខ្លួនឱ្យបានកាន់តែល្អប្រសើរថែមទៀត ហើយនៅក្នុងរបៀបវារៈចុងក្រោយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នឹងធ្វើការបូកសរុបនូវលទ្ធផលនៃអង្គសន្និបាតទាំងមូល រួមជាមួយនឹងការបង្ហាញពីយុទ្ធសាស្ត្រ និងវិធីសាស្ត្រវិទ្យាសាស្ត្រថ្មីៗមួយចំនួនក្នុងការពន្លឿនការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យមានប្រសិទ្ធភាពឆ្ពោះទៅសម្រេចបាននូវគោលដៅបីសូន្យ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ ការពិភាក្សា និងការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ក្នុងចំណោមសមាជិក សមាជិកានៃអង្គសន្និបាត ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅពេលនេះ និងសូមប្រសិទ្ធពរជូនឯកឧត្តម លោកជំទាវ លោក លោកស្រីភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ឱ្យមានសុខភាពល្អ កម្លាំងមាំមួនក្នុងការចូលរួមពិភាក្សាឱ្យបានផុសផុល ដើម្បីទទួលបាននូវលទ្ធផលទៅតាមកម្មវត្ថុ ដែលបានគ្រោងទុក និងសូមប្រកាសបើក "**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០១៩**" ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***